ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខៈ ១៤៩/១៦ គ.ជ.ប

# កំណត់ហេតុ
# វគ្គបណ្តុះបណ្តាល
# ស្តីពី
# ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស
# ដើម្បីផ្តល់សេវាសមស្រប
# សាលាខេត្តកណ្តាល ថ្ងៃទី២៦-២៨ ខែកញ្ញា ឆ្នាំ២០១៦

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែកញ្ញា ថ្ងៃទី២៦ វេលាម៉ោងប្រាំបី និងសាមសិបនាទី ព្រឹក នៅសាលប្រជុំសាលាខេត្តកណ្តាល មានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធាន គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ) មានការអញ្ជើញចូលរួមពីគ្រូឧទ្ទេស បណ្តាថ្នាក់ដឹកនាំ មន្ទីរជុំវិញខេត្ត អភិបាលស្រុក អធិការស្រុក ក្រុង និងអង្គភាព ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ** អភិបាល នៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធាន គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈអធិបតី និងគ្រូឧទ្ទេស ព្រមទាំងបណ្តាសិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលនាពេលនេះ។ ឯកឧត្តមបណ្ឌិត អភិបាល នៃគណៈអភិបាលខេត្ត បានថ្លែងកិច្ចស្វាគមន៍ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **លោកជំទាវ ជូ ប៊ុនអេង** ដែលបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់អញ្ជើញចូលរួមជាអធិបតីបើកវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់នៅខេត្តកណ្តាលនេះ។

ឯកឧត្តមបណ្ឌិត មានមតិបន្តទៀតថាៈ អំពើជួញដូរមនុស្ស មិនមែនជារឿងថ្មីឡើយ តែគឺជាភារកិច្ចរបស់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយជាតិដែលកំពុងតែនៅមានជាធរមាន រួមទាំងគោលនយោបាយ ភូមិ/ឃុំ មានសុវត្ថិភាពដែលបានដាក់បញ្ចូលរួចជាស្រេចនូវការទប់ស្កាត់ និងលុបបំបាត់អំពើជួញដូរមនុស្សនៅតាមបណ្តា ឃុំ/សង្កាត់។ ជារួមអំពើជួញដូរមនុស្សនៅកម្ពុជា ក៏ដូចជានៅខេត្តកណ្តាល មិនបានស្ងប់ស្ងាត់ សាបសូន្យនោះទេ គឺវាកំពុងតែមានសកម្មភាពរស់រវើក និងជ្រកកោនក្រោមសកម្មភាព និងរូបភាពជាច្រើន។

បន្ទាប់មក **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្ដៅ និងកោតសរសើរចំពោះ **ឯកឧត្តមបណ្ឌិត ម៉ៅ ធនិរុណា** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ) ព្រមទាំងបណ្ដាគ្រូឧទ្ទេស និងសិក្ខាកាមទាំងអស់ដែលបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនេះ ហើយសូមឲ្យសិក្ខាកាមទាំងអស់ត្រូវយកចិត្តទុកដាក់ ខិតខំស្វែងយល់ រាល់មេរៀនដែលគ្រូឧទ្ទេសបានបង្ហាត់បង្រៀនជូននាពេលនេះ ដើម្បីងាយស្រួលនៅពេលយើងបានបញ្ចប់វគ្គទៅ យើងនឹងអនុវត្តបានល្អក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងដើម្បីបង្ហាត់បង្ហាញបន្តដល់មន្ត្រីនៅក្នុងមូលដ្ឋានបន្ថែមទៀត។

**លោកជំទាវ ជូ ប៊ុនអេង** បានលើកឡើងពីផលលំបាកចំពោះពលករមួយចំនួនធំ ដែលកំពុងតែធ្វើការងារនៅក្រៅប្រទេស ខ្លះត្រូវបានគេបង្ខិតបង្ខំឲ្យធ្វើការងារគ្មានពេលសម្រាក ខ្លះទៀតត្រូវថៅកែមិនបើកប្រាក់ខែឲ្យ និងជាប់បំណុលគេរហូត។ ជាពិសេសពលករនេសាទត្រីនៅសមុទ្រពុំដែលបានឡើងគោក បើឈឺវិញរហូតដល់ស្លាប់ត្រូវថៅកែយកទៅក្លាសេក្នុងទឹកកករួចបោះចូលក្នុងសមុទ្រតែម្ដង មួយចំនួនទៀតត្រូវបានសមត្ថកិច្ចថៃចាប់ដាក់គុកគ្មានដំណឹងអ្វីសោះដល់គ្រួសារ ចំណែកពលករទ្រុឌទ្រោម គ្មានកម្លាំង អសមត្ថភាពការងារត្រូវគេបញ្ជូនមកប្រទេសវិញ ដោយគ្មាននៅសល់ប្រាក់កាសអ្វីសោះក្នុងខ្លួន ដែលធ្វើឲ្យក្រុមគ្រួសារ និងសង្គមជាតិទទួលរងនូវផលលំបាកយ៉ាងធ្ងន់ធ្ងរ។

**បន្ទាប់មក លោកជំទាវ បានធ្វើការបង្រៀននូវមេរៀនចំនួនពីរ គឺៈ**

**មេរៀនទីមួយៈ** ស្ដីពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សៈ ក្របខណ្ឌគោលនយោបាយច្បាប់ជាតិ អន្តរជាតិ និងយន្តការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ និងការទទួលខុសត្រូវ។

**មេរៀនទីពីរៈ** ស្ដីពីផែនការ និងយុទ្ធសាស្ត្រទាំងបួន យន្តការជួយជនរងគ្រោះ លទ្ធផល នៃការអនុវត្ត និងភាពប្រឈម។

ពេលរសៀល ថ្ងៃ ខែ ឆ្នាំ ដដែល **លោកឧត្តមសេនីយ៍ទោ ជីវ ផល្លី** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន បានឡើងឧទ្ទេសនាម ធ្វើបទបង្ហាញអំពីមេរៀន ស្ដីពីរបៀបសម្ភាសន៍ និងការបំពេញបែបបទនៃការសម្ភាសន៍ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ តាមទម្រង់ខ្លី និងទម្រង់លម្អិត បន្ទាប់មកលោកឧត្តមសេនីយ៍ទោបានដាក់សំនួរ ដល់សិក្ខាកាម។

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក **លោកស្រី កែវ ម៉ាលី** អនុប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានឡើងឧទ្ទេសនាម និងធ្វើបទបង្ហាញអំពីមេ**រៀនទីមួយៈ**ស្ដីពី តួនាទីមន្ត្រីសង្គមកិច្ច ក្នុងកិច្ចការពារជនរងគ្រោះ,**មេរៀនទីពីរៈ** ក្រមសីលធម៌ក្នុងការសម្ភាសន៍ និងសេវាដែលផ្ដល់ឲ្យជនរងគ្រោះ។

រសៀលថ្ងៃ ខែ ឆ្នាំ ដដែល តំណាងអង្គការ ទេសន្តប្រវេសន៍អន្តរជាតិ(IOM) បានឡើងឧទ្ទេសនាម និងធ្វើបទបង្ហាញមេរៀនស្ដីពី បទពិសោធន៍ក្នុងការជួយជនរងគ្រោះនៅក្រៅប្រទេស និងការបញ្ជូនត្រឡប់មកវិញ។ បន្ទាប់មកទៀត **លោកឧត្តមសេនីយ៍ត្រី គឹម ភាព** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

បានឡើងឧទ្ទេសនាម និងធ្វើបទបង្ហាញមេរៀន ស្តីពី គោលបំណង នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការកំណត់កេជាតុផ្សំបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ វគ្គបណ្តុះបណ្តាលបានធ្វើការបែងចែកជាក្រុម និងណែនាំសម្រាប់សាកល្បងបំពេញទម្រង់ខ្លី និងទម្រង់លម្អិត។ ក្រោយពីទទួលបានសំនួរសាកល្បងរួចមក តំណាងក្រុមនីមួយៗឡើងធ្វើការបកស្រាយ និងការពារការងារសាកល្បងដែលគ្រូឧទ្ទេសបានឲ្យបំពេញទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស តាមក្រុមនីមួយៗយ៉ាងផុលផុស។

ជាកិច្ចបញ្ចប់វគ្គបណ្តុះបណ្តាលនាពេលនេះ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ថ្លែងអំណរគុណចំពោះ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងគ្រូឧទ្ទេស ព្រមទាំងសិក្ខាកាមទាំងអស់ ដែលបានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ចំនួនបីថ្ងៃនេះទទួលបាននូវលទ្ធផលយ៉ាងល្អប្រសើរ។ លោកជំទាវ មានប្រសាសន៍ផ្តាំផ្ញើ ចំពោះសិក្ខាកាមដែលបានសិក្សារៀនសូត្រទាំងអស់នៅថ្ងៃនេះក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល ត្រូវប្តេជ្ញាចិត្តខិតខំជួយអប់រំបន្ត និងធ្វើការបង្ការទប់ស្កាត់ រាល់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅក្នុងមូលដ្ឋានរបស់ខ្លួនផង។

**លោកជំទាវ ជូ ប៊ុនអេង** បានមានប្រសាសន៍ជូនពរចំពោះ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត គ្រូឧទ្ទេស សិក្ខាកាម និងក្រុមការងារសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្នុងវគ្គបណ្តុះបណ្តាលនេះជួបប្រទះពុទ្ធពរទាំងបួនប្រការ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

វគ្គបណ្តុះបណ្តាលបានបញ្ចប់នៅវេលាម៉ោង ដប់ពីរ និងសាមសិបនាទី ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦
**អ្នកធ្វើកំណត់ហេតុ**

**គោរពជូន**
**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
រាជធានីភ្នំពេញ ថ្ងៃទី៣ ៤ខែកញ្ញា ឆ្នាំ២០១៦
ប្រធានលេខាធិការដ្ឋាន

ឧត្តមសេនីយ៍ត្រី គង់ ធុនី

៤៦៣
10/10/2016

# សមាសភាពអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល
# ស្តីពី
# ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស
# ដើម្បីផ្តល់សេវាសមស្រប

ពីថ្ងៃទី២៦-២៨ ខែកញ្ញាឆ្នាំ២០១៦ នៅសាលាខេត្តកណ្តាល

| | | |
|---|---|---|
| ១.លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ២.ឯ.ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៣.ឯ.ឧ បណ្ឌិត | ម៉ៅ ភិរុណ | អភិបាល នៃគណៈអភិបាលខេត្តកណ្តាល |
| ៤.ឯ.ឧ.ទោ | ស៊ុន រ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥.ល.ជ.ឧ.ទោ | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៦.ល.ជ | សួស សារ៉ាម | អភិបាលរងខេត្តកណ្តាល |
| ៧.លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច |
| ៨.លោក ឧ.ទោ | ជីវ ផល្លី | អនុប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរ និងការពារអនីតិជន |
| ៩.លោក ឧ.ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន កិច្ចការយុត្តិធម៌ គ.ជ.ប.ជ |
| ១០.លោក ឧ.ត្រី | គឹម ភាព | អនុប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរ និងការពារអនីតិជន |
| ១១.លោក ឧ.ត្រី | លី តុងហ៊ុយ | ប្រធាននាយកដ្ឋានការពារជនរងគ្រោះ គ.ជ.ប.ជ |
| ១២.លោក វ.ឯក | គង់ ស៊ីច័ន្ទ | អនុប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ១៣.លោក វ.ទោ | សេក ស៊ីវ៉េត | អនុប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ១៤.លោក | លី សុខជី | ប្រធានមន្ទីរសង្គមកិច្ចខេត្តកណ្តាល |
| ១៥.លោក | សៀក សារឿន | ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តកណ្តាល |
| ១៦.លោក | សាត សិទ្ធី | ប្រធានការិយាល័យ សង្គមកិច្ច |
| ១៧.លោក | ឃឹម សំភារ | អភិបាលរងស្រុកកណ្តាលស្ទឹង |
| ១៨.លោក វ.ទោ | ពក សាង | នាយសេនាធិការកងរាជអាវុធហត្ថខេត្តកណ្តាល |
| ១៩.លោក | មាស បាន | នាយការិយាល័យ កងរាជអាវុធហត្ថខេត្តកណ្តាល |
| ២០.លោក | ស៊ិន សារឿន | អនុប្រធានកង ៦០១ ក្អមសំណរ |
| ២១.លោក | អ៊ុន យ៉ុង | អធិការរង ស្រុកខ្សាចកណ្តាល |
| ២២.លោក | នូវ សារ៉ាវុធ | អធិការរង ស្រុកមុខកំពូល |
| ២៣.លោក | ឡុង ចាន់ថុល | អនុប្រធានមន្ទីរទេសចរណ៍ ខេត្តកណ្តាល |
| ២៤.លោក | ជា យ៉ុន | នាយរងការិយាល័យ ស្នងការដ្ឋាននគរបាលខេត្តកណ្តាល |

២៥.លោកស្រី សុខ សៅរិៈ អនុប្រធានមន្ទីរព័ត៌មាន ខេត្តកណ្តាល
២៦.លោក ស៊ឹម សារិទ្ធ អធិការរង ស្រុកលើកដែក
២៧.លោក អ៊ុយ ឈាង អធិការរង ស្រុកកោះធំ
២៨.លោក ផាច ផល្លា អធិការរង ស្រុកអង្គស្នួល
២៩.លោក ជា សាមឿន អធិការរង ស្រុកកណ្តាលស្ទឹង
៣០.លោក ជ័យ ស្រង់ អធិការរង ស្រុកពញាឮ
៣១.លោក លាង តារា អធិការរង ស្រុកល្វាឯម
៣២.លោក លន ចាន់ថា អធិការរង ស្រុកស្អាង
៣៣.លោក ស៊ិន សម្បត្តិ នាយកទីចាត់ការសាលាខេត្តកណ្តាល
៣៤.លោក គង្គ ច័ន្ទណែត អនុប្រធានការិយាល័យ សាលាខេត្ត
៣៥.លោក រស់ សារិន ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស ស្នងការដ្ឋានខេត្តកណ្តាល
៣៦.លោក ហេង ផេនិច្ច អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល
៣៧.លោកស្រី ឡុង ណារី អភិបាលរង ស្រុងមុខកំពូល
៣៨.លោកស្រី ជឹម អេង អភិបាលរង ស្រុកខ្សាច់កណ្តាល
៣៩.លោកស្រី ផៃ ច័ន្ទណារី អភិបាលរង ស្រុកកោះធំ
៤០.លោកស្រី ហង្ស ចន្ថា អភិបាលរង ស្រុកពញាឮ
៤១.លោកស្រី ពុទ្ធ សុខានី អភិបាលរង ស្រុកល្វាឯម
៤២.លោកស្រី ឃិន សុខន អភិបាលរងស្រុកអង្គស្នួល
៤៣.លោកស្រី ឯក តារា ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល
៤៤.លោកស្រី ឡេង សំបុណ្យ ប្រធានការិយាល័យមន្ទីរកិច្ចការនារី ខេត្តកណ្តាល
៤៥.លោកស្រី ងិន សុខា អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកណ្តាល
៤៦.លោកស្រី យឹម យុត្តិរី អភិបាលង ស្រុកស្អាង
៤៧.លោកស្រី ហែម សម្បត្តិ អភិបាលរង ក្រុងតាខ្មៅ
៤៨.លោកស្រី សុខ ខេង អនុប្រធានមន្ទីរការងារ ខេត្តកណ្តាល
៤៩.លោកស្រី គូ ម៉ានី អភិបាលរង ស្រុកលើកដែក
៥០.លោកស្រី គង់ ចាន់បុស្សិបា អនុប្រធានមន្ទីរ អ.យ.ក ខេត្តកណ្តាល
៥១.លោកស្រី វ៉ែន កន្និកា អភិបាលរង ស្រុកកៀនស្វាយ
៥២.លោក លឹម ងួនគ្រុយ អនុប្រធានមន្ទីរ កសិកម្មខេត្តកណ្តាល
៥៣.លោកស្រី ណឹម វណ្ណនី ស្នងការរង ស្នងការដ្ឋានខេត្តកណ្តាល

| | | |
|---|---|---|
| ៥៤.លោកស្រី | នួន នារតី | សមាជិកក្រុមប្រឹក្សាខេត្ត |
| ៦៥.លោក | លឹម សារ៉ុម | ប្រធានការិយាល័យមន្ទីរការងារខេត្តកណ្តាល |
| ៥៦.លោកស្រី | គឹម ណារី | អនុប្រធានមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល |
| ៥៧.លោក | ជរ វិចិត្រ | អនុប្រធានមន្ទីរសុខាភិបាលខេត្តកណ្តាល |
| ៥៨.លោកស្រី | ឡិញ មួយគាង | មន្ត្រីសាលាខេត្តកណ្តាល |
| ៥៩.លោក | ចំរើន កុរុណា | មន្ត្រីសាលាខេត្តកណ្តាល |
| ៦០.លោកស្រី | ឡៅ វណ្ណារ័ត្ន | ប្រធានមន្ទីរកិច្ចការនារី ខេត្តកណ្តាល |
| ៦១.លោក | សោម ស៊ីវរីន | មន្ត្រី គ.ជ.ប.ជ |
| ៦២.លោក វ.ត្រី | ឱកសត្យា | មន្ត្រី គ.ជ.ប.ជ |
| ៦៣.លោក | សៅ ស៊ីនួន | មន្ត្រី គ.ជ.ប.ជ |
| ៦៤.លោក | ហ៊ិន គឿន | នាយផ្នែក(ក្រុងតាខ្មៅ) |
| ៦៥.លោកស្រី | ម៉ម សុខា | មន្ត្រីជំនួយការ សាលាខេត្ត |

សរុបចំនួន: ៦៥ រូប, ស្រីចំនួន: ២៦ រូប